# ព្រះរាជាណាចក្រកម្ពុជា

រាជរដ្ឋាភិបាលកម្ពុជា ជាតិ សាសនា ព្រះមហាក្សត្រ

លេខ: ...៣៣...អនក្រ.បក

## អនុក្រឹត្យ

ស្តីពី

ការតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថាន ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ

---

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការរៀបចំ និការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី ២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រឹត្យ ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី ២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី ១៥ ខែ កុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ/បក ចុះថ្ងៃទី ៣០ ខែ មេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួង និង រដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ៥៧ អនក្រ/បក ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងបរិស្ថាន

## ស ម្រេ ច

**មាត្រា១: -**

ត្រូវបានតម្លើងនាយកដ្ឋានការពារ និងអភិរក្សធម្មជាតិ ទៅជាអគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិ របស់ក្រសួងបរិស្ថាន ។

**មាត្រា២: -**

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិមានភារកិច្ចទទួលបន្ទុក ក្នុងការគ្រប់គ្រង ការអភិរក្ស និង ការអភិវឌ្ឍតំបន់ការពារធម្មជាតិ ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា សំដៅធានា ការអភិរក្សធនធានធម្មជាតិ ជីវៈចម្រុះ និងធានាការប្រើប្រាស់ធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ ប្រកបដោយ និរន្តរភាព និងការរៀបចំវិធានសមស្របចាត់តាំងចាំបាច់ ដែលពាក់ព័ន្ធដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិក្នុងទូទាំងព្រះ រាជាណាចក្រកម្ពុជា ស្របតាមច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ ។

**មាត្រា៣ -**

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិដឹកនាំដោយ អគ្គនាយកមួយរូប និងអមដោយអគ្គនាយករង ជាជំនួយការ តាមការចាំបាច់ ។

អគ្គនាយកដ្ឋានរដ្ឋបាលការពារ និងអភិរក្សធម្មជាតិរបស់ក្រសួងបរិស្ថានមាននាយកដ្ឋានចំណុះចំនួនប្រាំ(៥):

១- នាយកដ្ឋាន រដ្ឋបាល ផែនការ គណនេយ្យ និងហិរញ្ញវត្ថុ

២- នាយកដ្ឋាន ឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ

៣- នាយកដ្ឋាន ស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ

៤- នាយកដ្ឋាន អនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ

៥- នាយកដ្ឋាន តំបន់ដីសើម និងតំបន់ឆ្នេរ

**មាត្រា៤ -**

នាយកដ្ឋាន រដ្ឋបាល ផែនការ គណនេយ្យ និងហិរញ្ញវត្ថុ មានភារកិច្ច :

- ធ្វើផែនការយុទ្ធសាស្ត្ររយៈពេលវែង និងខ្លី សម្រាប់ការគ្រប់គ្រង ការពារ អភិរក្ស និងអភិវឌ្ឍក្នុងតំបន់ ការពារធម្មជាតិ

- ធ្វើផែនការសកម្មភាពការងារគ្រប់គ្រង ការកំណត់តំបន់ សាងសង់ស្នាក់ការតាមតំបន់ការពារធម្មជាតិ និង តាមដាន ត្រួតពិនិត្យការអនុវត្តផែនការ

- លើកគម្រោងថវិកាសម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ តាមដានរំលឹកពីការប្រតិបត្តិ និងការបង្កើត មូលនិធិតំបន់ការពារធម្មជាតិ

- គ្រប់គ្រង និងចរាចរឯកសាររដ្ឋបាលផ្សេងៗរបស់អគ្គនាយកដ្ឋាន

- ចូលរួមរាយការណ៍ការងារគ្រប់គ្រងតំបន់ការពារធម្មជាតិ និងសកម្មភាពផ្សេងៗរបស់អគ្គនាយកដ្ឋាន

- ប្រមូលចំណូលឱ្យបានសមស្របតាមច្បាប់ហិរញ្ញវត្ថុ និងតាមដានរំលឹកការគ្រប់គ្រងគណនីពិសេស
- ប្រមូលផ្តុំ និងសម្របសម្រួលជំពូកថវិកា និងរាល់ចំណាយរបស់អគ្គនាយកដ្ឋាន
- ប្រមូលផ្តុំតម្រូវការធ្វើកម្មវិធី ចំណាយ គ្រប់គ្រងការរៀបចំចូលជុលសម្ភារៈ និងធ្វើបញ្ជីសារពើភ័ណ្ឌ
- រៀបចំកសាង ពិនិត្យ កែសម្រួល សេចក្តីព្រាងច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត សម្រាប់ការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើសលើធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់ការពារធម្មជាតិតាមនីតិវិធី ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

នាយកដ្ឋាន រដ្ឋបាល ផែនការ គណនេយ្យ និងហិរញ្ញវត្ថុ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

**មាត្រា៥–**

នាយកដ្ឋាន ឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ មានភារកិច្ច :

- រៀបចំយុទ្ធសាស្ត្រ ផែនការសកម្មភាព និងគោលការណ៍ណែនាំបច្ចេកទេស សម្រាប់គ្រប់គ្រងតំបន់ការពារធម្មជាតិ និងរៀបចំការកំណត់ព្រំប្រទល់ ធ្វើផែនទីតំបន់ការពារធម្មជាតិ ព្រមទាំងធ្វើការកំណត់តំបន់គ្រប់គ្រង នៅតាមតំបន់ការពារធម្មជាតិនីមួយៗ ដោយសហការជាមួយស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរដែនដី ឬ អង្គការអន្តរជាតិ
- សិក្សា ស្រាវជ្រាវ និងរៀបចំទិន្នន័យប្រភេទសត្វ រុក្ខជាតិ ប្រភេទដែលកម្រ និងប្រភេទជិតផុតពូជនៅក្នុងតំបន់ការពារធម្មជាតិ
- រៀបចំគម្រោងកម្មវិធីស្វែងរកជំនួយថវិកា និងបច្ចេកទេសពីបណ្តាប្រទេស ឬ អង្គការជាតិ អន្តរជាតិនានា ដើម្បីគាំទ្រដល់ការគ្រប់គ្រងតំបន់ការពារធម្មជាតិនីមួយៗប្រកបដោយនិរន្តរភាព
- ត្រួតពិនិត្យលិខិតអនុញ្ញាត និងឯកសារផ្សេងៗ ដែលបានកំណត់ដោយច្បាប់ ស្តីពីតំបន់ការពារធម្មជាតិ និងមានវិធានការទប់ស្កាត់ភ្លើងឆេះព្រៃក្នុងតំបន់ការពារធម្មជាតិ
- ធ្វើការអប់រំផ្សព្វផ្សាយដល់សាធារណជន ក្នុងការចូលរួមថែរក្សា ការពារធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងផ្សព្វផ្សាយ ត្រួតពិនិត្យការអនុវត្តច្បាប់ អនុក្រឹត្យ បរិធានច្បាប់នានា និងគោលការណ៍ណែនាំបច្ចេកទេសក្នុងការគ្រប់គ្រងតំបន់ការពារធម្មជាតិ
- ចាត់វិធានការដើម្បីស្រាវជ្រាវ ទប់ស្កាត់ និងបង្ក្រាបបទល្មើសលើធនធានធម្មជាតិក្នុងតំបន់ការពារធម្មជាតិ និងកសាងសំណុំរឿងបញ្ជូនទៅតុលាការ ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីច្បាប់ ។
- រៀបចំសំណុំរឿង និងដោះស្រាយបទល្មើសលើធនធានធម្មជាតិ និងបរិស្ថានក្នុងតំបន់ការពារធម្មជាតិតាមនីតិវិធី ក្នុងនាមជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមក្រមនីតិវិធីព្រហ្មទណ្ឌនៃព្រះរាជាណាចក្រកម្ពុជា ។

នាយកដ្ឋានឧទ្យានជាតិ និងដែនជម្រកសត្វព្រៃ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

មាត្រា៦ -

នាយកដ្ឋានស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ មានភារកិច្ច :

- រៀបចំកិច្ចព្រមព្រៀង និងលក្ខន្តិកៈ ស្តីពីកម្មវិធីអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ

- ធ្វើការអប់រំផ្សព្វផ្សាយ និងសម្របសម្រួលជាមួយសហគមន៍មូលដ្ឋាន និងជនជាតិដើមភាគតិចក្នុងដំណើរការរៀបចំ និងការអនុវត្តរបស់សហគមន៍តំបន់ការពារធម្មជាតិ

- រៀបចំកសាងគោលការណ៍ណែនាំ ស្តីពីនីតិវិធី និងដំណើរការរៀបចំសហគមន៍តំបន់ការពារធម្មជាតិ

- រៀបចំផែនការយុទ្ធសាស្ត្រ ដើម្បីអនុវត្តកម្មវិធីអភិវឌ្ឍន៍ការគ្រប់គ្រងធនធានធម្មជាតិ និងសហគមន៍តំបន់ការពារធម្មជាតិ ដោយមានការចូលរួម សំដៅលើកស្ទួយការការពារធនធានធម្មជាតិប្រកបដោយប្រសិទ្ធភាពខ្ពស់

- ជម្រុញឱ្យមានការចូលរួមគាំទ្រ និងលើកទឹកចិត្តដល់សហគមន៍មូលដ្ឋាន ក្នុងការរៀបចំគម្រោងអភិវឌ្ឍសហគមន៍តំបន់ការពារធម្មជាតិ និងគ្រប់គ្រងធនធានធម្មជាតិដោយមានការចូលរួម និងសហការពីអាជ្ញាធរដែនដី ស្ថាប័នជំនាញពាក់ព័ន្ធ អង្គការក្រៅរដ្ឋាភិបាលជាតិ អន្តរជាតិនានា

- រៀបចំកម្មវិធី និងផ្តល់ការបណ្តុះបណ្តាល ស្តីពីសហគមន៍តំបន់ការពារធម្មជាតិ និងការគ្រប់គ្រងធនធានធម្មជាតិ ដល់មន្ត្រីថ្នាក់ជាតិ ខេត្ត មូលដ្ឋាន និងជនជាតិដើមភាគតិច

- មានវិធានការ ចូលរួមសហការក្នុងការទប់ស្កាត់ និងបង្ក្រាបបទល្មើសគ្រប់រូបភាពនៅក្នុងសហគមន៍តំបន់ការពារធម្មជាតិ ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីគតិយុត្ត។

នាយកដ្ឋាន ស្រាវជ្រាវ និងអភិវឌ្ឍន៍សហគមន៍តំបន់ការពារធម្មជាតិ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងគមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

មាត្រា៧ -

នាយកដ្ឋាន អនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ មានភារកិច្ច :

- រៀបចំកម្មវិធីអប់រំ ផ្សព្វផ្សាយតាមគ្រប់រូបភាពឱ្យបានទូលំទូលាយ ស្តីពីកិច្ចការពារ និងអភិរក្សធនធានធម្មជាតិ ការស្តារ ការកែលំអធនធានជីវៈចម្រុះឡើងវិញ និងប្រព័ន្ធអេកូឡូស៊ីដែលបានរេចរឹល និងបាត់បង់ និងរៀបចំសកម្មភាពស្តារឡើងវិញនូវធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ នៅរៀងរាល់ឆ្នាំក្នុងទិវាបរិស្ថានជាតិ បរិស្ថានពិភពលោក និងទិវាអនុសញ្ញាជាតិ អន្តរជាតិនានា។

- អនុវត្តតាមគោលការណ៍អនុសញ្ញាអន្តរជាតិ ជាពិសេសអនុសញ្ញា ស្តីពីជីវៈចម្រុះ ពិធីសារ និងកិច្ចព្រមព្រៀងទ្វេភាគី ឬ ពហុភាគីឱ្យមានប្រសិទ្ធភាព

- ទំនាក់ទំនង និងសហការ សម្របសម្រួលការងារជាមួយស្ថាប័នពាក់ព័ន្ធ អង្គការជាតិ និងអន្តរជាតិនានា ដើម្បីស្នើសុំ ជំនួយថវិកា សម្រាប់អនុវត្តអនុសញ្ញាអន្តរជាតិ ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ ឬថ្នាក់តំបន់

- ពិនិត្យ ផ្តល់យោបល់ និងកែសម្រួលលើឯកសារគោលនយោបាយ ការសម្រេចចិត្ត របាយការណ៍បច្ចេកទេស និង របាយការណ៍ពាក់ព័ន្ធនានា តាមការស្នើរបស់លេខាធិការដ្ឋាននៃអនុសញ្ញាអន្តរជាតិ និងលើកការស្នើសុំរៀបចំកែប្រែ

តំបន់ការពារធម្មជាតិណាមួយ តាមតម្រូវការរបស់រាជរដ្ឋាភិបាល ឬ អនុលោមទៅតាមអនុសញ្ញា ពិធីសារ កិច្ចព្រមព្រៀងថ្នាក់តំបន់ និងអន្តរជាតិ

- តាមដាន ត្រួតពិនិត្យ និងអនុវត្តច្បាប់ ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីគតិយុត្ត ក្នុងការគ្រប់គ្រងធនធានជីវៈចម្រុះ និងធនធានធម្មជាតិនានាក្នុងតំបន់ការពារធម្មជាតិ និងវាយតម្លៃលើការអនុវត្តអនុសញ្ញា ពិធីសារ និងកិច្ចព្រមព្រៀងអន្តរជាតិ ឬថ្នាក់តំបន់

- រៀបចំយន្តការសម្រាប់ជម្រុញ និងសម្របសម្រួល ដល់កិច្ចសហប្រតិបត្តិការវិទ្យាសាស្ត្រ និងបច្ចេកទេស ការផ្លាស់ប្តូរព័ត៌មាន និងការពង្រឹងបណ្តាញការងារនៅថ្នាក់ជាតិ ថ្នាក់តំបន់ និងថ្នាក់អន្តរជាតិ ។

នាយកដ្ឋានអនុសញ្ញាអន្តរជាតិ និងជីវៈចម្រុះ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋានជាជំនួយការតាមការចាំបាច់ ។

**មាត្រា៨ –**

នាយកដ្ឋាន តំបន់ដីសើម និងតំបន់ឆ្នេរ មានភារកិច្ច :

- រៀបចំផែនការយុទ្ធសាស្ត្រ និងផែនការសកម្មភាព សម្រាប់ការគ្រប់គ្រង ការពារ អភិរក្ស និងប្រើប្រាស់ធនធានធម្មជាតិនៅក្នុងតំបន់ដីសើម និងឋបនីយជីវមណ្ឌលប្រកបដោយនិរន្តរភាព និងសិក្សាស្រាវជ្រាវពីធនធានធម្មជាតិ សេដ្ឋកិច្ច សង្គម ដែលមាននៅក្នុងតំបន់ដីសើម ទីជម្រាល និងតំបន់ឆ្នេរ

- រៀបចំកម្មវិធីបណ្តុះបណ្តាលជំនាញដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌលដល់មន្ត្រីជំនាញ និងជម្រុញការផ្សព្វផ្សាយពីសារៈប្រយោជន៍ និងតម្លៃនៃធនធានដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌល ដល់សាធារណជនគ្រប់ខេត្ត ក្រុង និងក្រុមហ៊ុនឯកជន ។ល។

- មានវិធានការណ៍ល្បាត ទប់ស្កាត់រាល់សកម្មភាពខុសច្បាប់គ្រប់រូបភាព និងដោះស្រាយបាតុភាពផ្សេងៗនៅក្នុងតំបន់ដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌល និងអនុវត្តការដាក់ពិន័យ រៀបចំសំណុំរឿងបញ្ជូនទៅតុលាការនូវរាល់បទល្មើស ដែលកើតមាននៅក្នុងតំបន់ដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌល ក្នុងនីតិសម្បទាជាមន្ត្រីនគរបាលយុត្តិធម៌ ស្របតាមនីតិវិធីគតិយុត្ត

- ត្រួតពិនិត្យ និងអនុវត្តផែនការបរិស្ថានជាតិ ផែនការដីសើម និងផែនការនានាដែលពាក់ព័ន្ធសម្រាប់ការគ្រប់គ្រង ការពារ អភិរក្ស និងប្រើប្រាស់ធនធានតំបន់ដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌលបានប្រកបដោយនិរន្តរភាព និងរៀបចំចងក្រងទិន្នន័យព័ត៌មានស្តីពីធនធានតំបន់ដីសើម ទីជម្រាល តំបន់ឆ្នេរ និងឋបនីយជីវមណ្ឌល។

នាយកដ្ឋាន តំបន់ដីសើម និងតំបន់ឆ្នេរ ដឹកនាំដោយប្រធាននាយកដ្ឋាន ០១រូប និងអមដោយអនុប្រធាននាយកដ្ឋាន ជាជំនួយការតាមការចាំបាច់ ។

**មាត្រា៩ –**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា១០-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋលេខាធិការ នៃរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ រដ្ឋមន្ត្រី និងរដ្ឋលេខាធិការ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

**មាត្រា១១-**

អនុក្រឹត្យនេះ ចូលជាធរមានចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មេសា ឆ្នាំ ២០០៨

នាយករដ្ឋមន្ត្រី

សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន

បានយកសេចក្តីជម្រាបជូន សម្តេចនាយករដ្ឋមន្ត្រី

ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងបរិស្ថាន

បណ្ឌិត ម៉ុក ម៉ារ៉េត

<u>កន្លែងទទួល</u> :

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋាន ព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋាន រដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១០
- រាជកិច្ច
- ឯកសារ. កាលប្បវត្តិ